ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
12 / 12 / 2016
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/479

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៤៦០

រៀបចំដោយ៖ លោកស្រី សែ កុលវុឌ្ឍី និង កញ្ញា Maddalena GHEZZI

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ,ចៅក្រម ធូ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin Karopkin |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Dale LYSAK, លោក សេង លាង, លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោកស្រី Doreen CHEN |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD |

| |
|---|
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ 2-TCW-1036 (សាក្សីប្រភេទ "ក") |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី ស្នួរ សុទ្ធារី |
| ផ្សេងៗ៖ លោក កែវ រ៉ាត, លោក នូ មនោរ័ត្ន, កញ្ញា យស់ សេរីរ័ត្ន, លោក សុខ សុភ័ក្រ, លោក Sebastian BATES |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១១.០៣ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.២២ | បញ្ចប់ម៉ោង៖ ១០.៤៧ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០១ ម៉ោង និង ៣៦ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ | ០៩.០៣ | ០៩.០៥ |
| សេចក្តីសម្រេចផ្ទាល់មាត់ក្នុងការកោះហៅសាក្សី 2-TCW-1065 | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.០៧ |
| ការតាំងសំណួរទៅសាក្សី 2-TCW-1036 | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៧<br>០៩.២៩<br>០៩.២៩<br>០៩.៤៥ | ០៩.២៩<br>០៩.២៩<br>០៩.៤៥<br>១០.២១ |
| សារណាផ្ទាល់មាត់ទៅលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ក្នុងការផ្អាកការស្តាប់ចម្លើយដើមបណ្តឹង 2-TCCP-1064 | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | ១០.៤៧<br>១០.៤៩<br>១០.៥២<br>១០.៥៣ | ១០.៤៩<br>១០.៥២<br>១០.៥៣<br>១០.៥៣ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្តី ខៀវ សំផន | ១០.៥៣ | ១០.៥៤ |
| | សហមេធាវីនាំមុខ | ១០.៥៤ | ១០.៥៥ |
| | អង្គជំនុំជម្រះ | ១០.៥៥ | ១០.៥៧ |
| | សហមេធាវីនាំមុខ | ១០.៥៧ | ១០.៥៧ |
| | អង្គជំនុំជម្រះ | ១០.៥៧ | ១០.៥៧ |
| | សហព្រះរាជអាជ្ញា | ១០.៥៧ | ១១.00 |
| | មេធាវីការពារក្តី នួន ជា | ១១.00 | ១១.00 |
| | អង្គជំនុំជម្រះ | ១១.00 | ១១.0៣ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន ។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សេចក្តីសម្រេចផ្ទាល់មាត់ក្នុងការកោះហៅសាក្សី 2-TCW-1065**

អង្គជំនុំជម្រះបានសម្រេចកោះហៅសាក្សី 2-TCW-1065 ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន និងបានទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះធ្វើជាឯកសារភស្តុតាង (E3/10667, E3/10668, E3/10669) ។

**ការបន្តតាំងសំណួរទៅសាក្សី 2-TCW-1036**

សហព្រះរាជអាជ្ញា មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងមេធាវីការពារក្តី ខៀវ សំផនបានតាំងសំណួរទៅកាន់ 2-TCW-1036។

**សារណាផ្ទាល់មាត់ទៅលើសំណើរសុំរបស់មេធាវីការពារក្តី នួន ជា**

អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់ទៅលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា សុំពន្យារការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1064។ អង្គជំនុំជម្រះសម្រេចតាមសំណើសុំនេះ។

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1208 | / | 00020901; 00539059; 00532777 | Telegram 63 To respected Angkar 870 about picking up the son of a Foreign Affairs staffer | P | 00020901 | 00539059 | 00532777 |
| E3/4202 | E152.2 | 00858214-00858410; 00757471-00757568; 00849349-00849484 | Book by GINA Chon and THET Sambath entitled "Behind the killing fields: a Khmer Rouge leader and one of his victims" | P | 00858392 | 00757552 | 00849470 |
| E3/9581 | E319/19.3.107 | 00960674-00960685; 00970077-00970089; 01044641-01044651 | Written Record of Interview of **[Redacted]** | C | 00960683-00960684 | 00970088 | 01044650 |
| E3/10604 | / | 01222328-01222936 (ENG) | Annex 2: OCIJ S-21 Prisoners List 31 March 2016 | P | / | 01222407 | / |
| E3/863 | / | 00076286-00076288; 00321961-00321963; 00623408-00623410 | To Respected Angkar: about defending the enemy | P | 00076287 | 00321962 | 00623409 |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៥)
- សេចក្ដីសម្រេចផ្ទាល់មាត់ក្នុងការកោះហៅសាក្សី 2-TCW-1065 និងទទួលយកឯកសារ E3/10667, E3/10668 និង E3/10669 ជាឯកសារភ័ស្តុតាង។ (០៩.០៧)
- សម្រេចពន្យារពេលស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1064 (១១.០២)

01362562



- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃ អង្គារ៍ ទី ០៤ ខែ តុលា ឆ្នាំ ២០១៦។ (១១.0៣)

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង 0៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ សុវណ្ណ័រ៉ូតា លោកស្រី Maddalena GHEZZI